លេខ ៤៩ ចេញផ្សាយថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកក្កដា ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥"ទំព័រទី១.......... ទំព័រទី១
- សិក្ខាសាលាស្តីពី "ការធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០"......... ទំព័រទី២
- វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"......... ទំព័រទី២
- ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល"......... ទំព័រទី២
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមហ៊ុនស្ថាប័ន Kathmandu FinteK នៃប្រទេសនេប៉ាល......... ទំព័រទី៣
- កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត"......... ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤......... ទំព័រទី៣
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ......... ទំព័រទី៤
- កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៥......... ទំព័រទី៤
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "កិច្ចសហ-ប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន"......... ទំព័រទី៤
- សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២៥ របស់អង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១"......... ទំព័រទី៥
- ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគាររដ្ឋបាលក្រុមប្រឹក្សាជាតិគាំពារសង្គម......... ទំព័រទី៥
- កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ លើកទី១០ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា......... ទំព័រទី៦
- កិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២៥......... ទំព័រទី៦
- សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"......... ទំព័រទី៦
- វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"......... ទំព័រទី៧
- សិក្ខាសាលាស្តីពី "ការបំពេញបន្ថែមលើប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព"......... ទំព័រទី៧
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ......... ទំព័រទី៨
- សន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤......... ទំព័រទី៨
- វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៧......... ទំព័រទី៨
- កិច្ចប្រជុំជំនួយបច្ចេកទេស (TA) ស្តីពី "ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"......... ទំព័រទី៩
- សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "អនុសាសន៍ទី១៨, ទី១៩, ទី២០,ទី២១ និងទី២៣ និងលទ្ធផលដាក់ស្តែងទី៤"......... ទំព័រទី៩
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិង
- ពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៥......... ទំព័រទី៩
- កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៧ ឆ្នាំ២០២៥......... ទំព័រទី៩
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ......... ទំព័រទី១០
- កិច្ចប្រជុំស្តីពី "ប្រតិបត្តិការហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្រោមគម្រោង
- ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"......... ទំព័រទី១០
- សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង,
- ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"......... ទំព័រទី១១
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំ
- ខែសីហា ឆ្នាំ២០២៥......... ទំព័រទី១១
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងក្រុមហ៊ុន VTeam Financial Services Group......... ទំព័រទី១១


## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥"

នាព្រឹកថ្ងៃអង្គារ ៦កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ឌី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅសណ្ឋាគារ ភ្នំពេញ។




រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាស្ដីពី "ការធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០"

នាថ្ងៃព្រហស្បតិ៍ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែកក្កដា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណើ សារកល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាស្តីពី "ការធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ច័ន្ទតីរូ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា នៅសណ្ឋាគារសុខា ភ្នំពេញ។




រូបភាព៖ សិក្ខាសាលាស្តីពី "ការធ្វើបច្ចុប្បន្នកម្ម ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០"។

## វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

ចាប់ពីថ្ងៃព្រហស្បតិ៍ ៨កើត ដល់ថ្ងៃសុក្រ ៩កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣-៤ ខែកក្កដា គ.ស. ២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1), **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" ដល់មន្ត្រីបង្គោលនៃធនាគារធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា ភីអិលស៊ី នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ។

វគ្គបណ្តុះបណ្តាលនេះ បានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹង ក៏ដូចជាពង្រឹងសមត្ថភាពដល់មន្ត្រីនៃធនាគារដៃគូទាំងពីរ មកពីទូទាំងខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ជាខេត្តគោលដៅថ្មីលើការរៀបចំបំពេញព័ត៌មាន ក្នុងទម្រង់ផលប៉ះពាល់ដល់បរិស្ថាន និងសុវត្ថិភាពសង្គម ដែលជាលក្ខខណ្ឌតម្រូវក្នុងការស្នើសុំឥណទាន និងនីតិវិធីប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្នុងក្របខណ្ឌគម្រោង ACSEP សមាសភាគទី១។ សូមបញ្ជាក់ជូនផងដែរថា គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1) ត្រូវបានពង្រីកវិសាលភាពដល់កម្រិតទូទាំងប្រទេស ដែលខេត្តទាំងពីរខាងលើជាខេត្តគោលដៅថ្មីបន្ថែម លើខេត្តគោលដៅទាំង ៦ ដែលមានស្រាប់។

វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃខេត្តទាំង ២ និងក្រុមការងារមកពីតាមបណ្តាខេត្តគោលដៅនៃស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) និងនីតិវិធីឥណទានក្នុងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"។

## ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុម-នីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល"

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមក្នុង "ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យ និងយុទ្ធ-សាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភា-ចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច**

និងហិរញ្ញវត្ថុនិងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរ-ធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។



រូបភាព៖ ពិធីប្រកាសដាក់ឱ្យអនុវត្តចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពីសុខដុមនី-យកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល”។

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមហ៊ុនស្ថាប័ន Kathmandu FinteK នៃប្រទេសនេប៉ាល

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា គ.ស.២០២៥, **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានទទួលជួបពិភាក្សាការងារពាក់ព័ន្ធនឹងការបណ្តុះបណ្តាលបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech) ជាមួយ **លោក Sanjib Subba** ស្ថាបនិកនៃស្ថាប័ន Kathmandu FinteK នៃប្រទេសនេប៉ាល នៅទីស្តីការ **ន.ប.ធ.**។



រូបភាព៖កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមហ៊ុនស្ថាប័នKathmandu FinteK នៃប្រទេសនេប៉ាល។

## កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត"

នាព្រឹកថ្ងៃពុធ ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា គ.ស.២០២៥, **ន.ប.ធ.** បានរៀបចំកិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (Business Development Center-BDC)។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញអំពីសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅឆមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។

នៅចុងបញ្ចប់នៃកម្មវិធី **ន.ប.ធ.** ក៏បានចែកជូននូវបណ្ណសរសើរជូនដល់មន្ត្រីឆ្នើមដែលបានបំពេញការងារលេចធ្លោ ទទួលខុសត្រូវខ្ពស់ ទៀងទាត់ពេលវេលា ទំនាក់ទំនងល្អ និងលះបង់ខ្ពស់ដើម្បីស្ថាប័ន។



រូបភាព៖ កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត"។

## កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើតខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**

អមដោយសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តី-ព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ជូ គឹមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ.

នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋ-មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយកដែលជាសមាជិក-សមាជិកានៃ **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ.។

## កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៥

នៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ **លោក យុន-វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៥ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម យ៉េត ទីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ **អគហ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារ Reffles Le Royal។



រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ-២០២៥។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "កិច្ចសហ-ប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន"

នារសៀលថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "កិច្ចសហប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន" រវាងនិយ័ត-ករមូលបត្រកម្ពុជាដែលតំណាងដោយ **ឯកឧត្តម ស៊ូ សុជាតិ**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃ **ន.ម.ភ.** និងក្រសួងព័ត៌មានដែលតំណាងដោយ **ឯកឧត្តម នេត្រ ភក្ត្រា** នៅទីស្តីការក្រសួងព័ត៌មាន។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "កិច្ចសហប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន"។

## សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ-២០២៥ របស់អង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១"

នាព្រឹកថ្ងៃសុក្រ ១ រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា គ.ស.២០២៥ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២៥ របស់អង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជានាយកគម្រោង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **លោក-ឡុង ពិសិដ្ឋ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB និងជាប្រធានគ្រប់គ្រងគម្រោង ACSEP ប្រចាំប្រទេសកម្ពុជា** និង**លោក ណូ លីជា អគ្គនាយកនៃសាជីវកម្មធានាឥណទានកម្ពុជា (CGCC)** នៅសណ្ឋាគារកាប៊ូឌី-យ៉ាណា ភ្នំពេញ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិភាក្សាលើបញ្ហាប្រឈម កាលានុវត្តភាព និងដំណោះស្រាយ ដែលបានអនុវត្តកន្លងមក និងសំណូមពរនានារបស់អង្គភាពពាក់ព័ន្ធជាពិសេសស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ ក្នុងដំណើរការអនុវត្តគម្រោងពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការផ្នែកឥណទានក្នុងឆ្នាំ២០២៥ ដើម្បីឈានទៅរកដំណោះស្រាយសមស្របរួមគ្នាមួយសម្រាប់ការរៀបចំយុទ្ធសាស្ត្រអនុវត្តឱ្យបានកាន់តែល្អប្រសើរថែមទៀត។

សិក្ខាសាលានេះក៏បានពិភាក្សាសម្រាប់ក្របខណ្ឌអនុវត្តការងារនៅក្នុងឆមាសទី២ បន្តក្នុងក្របខណ្ឌខេត្តគោលដៅថ្មីចំនួន ៨ រួមមាន៖ ខេត្តក្រចេះ ស្ទឹងត្រែង កំពង់ស្ពឺ តាកែវ កណ្តាល បាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ ដែលបានពង្រីកវិសាលភាព និងត្រៀមពង្រីកវិសាលភាពទៅដល់ខេត្តទូទាំងប្រទេស។ បច្ចុប្បន្ន អង្គភាពអនុវត្តគម្រោង (ACSEP-PIU1) បានផ្តល់ឥណទានដែលសរុបជាទឹកប្រាក់មានចំនួន ៩.៨ លានដុល្លារអាមេរិក ដល់អតិថិជនចំនួន ៥១៧ រូប សម្រាប់ប្រើប្រាស់ក្នុងខ្សែច្រវាក់តម្លៃផលិតផលកសិកម្មគោលដៅចំនួន ៥ ៖ ស្វាយចន្ទី មាន់ស្រែ ដំឡូងមី បន្លែ និងស្វាយ តាមរយៈដៃគូស្ថាប័នហិរញ្ញវត្ថុដៃគូទាំង ២។ តាមរយៈការអនុវត្តដោយលទ្ធផលល្អប្រសើរនេះ គម្រោងនេះត្រូវបានពង្រីកវិសាលភាពដល់កម្រិតទូទាំងប្រទេស នៅក្នុងឆ្នាំ២០២៥។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការជាតិ និងគ្រប់គ្រងបំណុល (GDICDM), អង្គភាពគ្រប់គ្រងគម្រោងមកពី PIU2, ទីប្រឹក្សាគម្រោង (AVCC), តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តគោលដៅចាស់ទាំង ៦ និងខេត្តគោលដៅថ្មី និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២៥ របស់អង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១"។

## ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគាររដ្ឋបាលក្រុម-ប្រឹក្សាជាតិគាំពារសង្គម

នាព្រឹកថ្ងៃសៅរ៍ ២រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេឡាធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគាររដ្ឋបាលក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពៈ ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគាររដ្ឋបាលក្រុមប្រឹក្សាជាតិគាំពារសង្គម។

## កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ លើកទី១០ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា

នាព្រឹកថ្ងៃចន្ទ ៤រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកនៃក្រុមការងារមណ្ឌលហិរញ្ញវត្ថុ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ លើកទី១០ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** នៅទីស្តីការនៃ **អ.ស.ហ.**។



រូបភាពៈ កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ លើកទី១០ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា។

## កិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២៥

នៅព្រឹកថ្ងៃអង្គារ ៥រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពៈ កិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២៥។

## សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យធនធានមនុស្ស បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងលោកបណ្ឌិត ជា សុភាព សាកលវិទ្យាធិការនៃសាកលវិទ្យាល័យធនធានមនុស្ស នៅសាកល

វិទ្យាល័យធនធានមនុស្ស។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្ដល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក សាធ ភីរ៉ាត ប្រធាននាយកដ្ឋានប្រតិបត្តិការពាណិជ្ជលក់រាយ** វាគ្មិនតំណាងពីធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យធនធានមនុស្ស។



**រូបភាព៖** សិក្ខាសាលាស្ដីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"។

## វគ្គបណ្ដុះបណ្ដាលស្ដីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម ណី សារកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច បានដឹកនាំក្រុមការងារនៃ **ន.ប.ធ.** ចូលរួមកម្មវិធីបណ្ដុះបណ្ដាលស្ដីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ដែលជាធនាគារទទួលបានអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្មពី **ន.ប.ធ.**។ កម្មវិធីបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំនៅសណ្ឋាគារ ភ្នំពេញ អេរ៉ា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។





**រូបភាព៖** វគ្គបណ្ដុះបណ្ដាលស្ដីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## សិក្ខាសាលាស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព"

នាព្រឹកថ្ងៃសុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងប្រកាសស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ក្នុងគោលបំណងទទួលបានមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ជាពិសេសអ្នកអនុវត្តការងារផ្ទាល់ ដើម្បីឱ្យសេចក្ដីព្រាងប្រកាសខាងលើកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយសំដៅដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលាពិគ្រោះយោបល់នេះ មានការចូលរួមពីតំណាងក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្ដល់សេវាសុវត្ថិភាពឬរក្សាទុក, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច។





**រូបភាព៖** សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងប្រកាសស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃសុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យស្តីពី "មូលដ្ឋាននៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គមរបស់និយ័តករសន្តិសុខសង្គម (**ន.ស.ស.**)" និងសេចក្តីព្រាងប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំអនុញ្ញាតរបស់ក្រុមហ៊ុន ឬសហគ្រាសធ្វើអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន របស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ (**ន.អ.ប.**)" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។




រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## សន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤

នាថ្ងៃសុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**អមដោយសហការី បានអញ្ជើញចូលរួមសន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រុមហ៊ុនគណនេយ្យ និងសវនកម្ម ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទ **គសបាខ** និងបណ្តាប្រទេសជាសមាជិកអាស៊ាន នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា។



រូបភាព៖ សន្និសីទគណនេយ្យករជំនាញអាស៊ានលើកទី៤។

## វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៧

នាព្រឹកថ្ងៃចន្ទ ១១រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៧" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំរយៈពេលចំនួន ៣ ថ្ងៃពេញ ចាប់ពីថ្ងៃទី២១-២៣ ខែកក្កដា ឆ្នាំ២០២៥ និងមានអ្នកចូលរួមសរុបចំនួន ១២០ រូប (សិក្ខាកាមជនជាតិបរទេស ១០ រូប) ដែលមានសមាសភាពចូលរួមពីក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច, បុគ្គលដែលមានបំណងផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន។



រូបភាព៖ វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៧។

## កិច្ចប្រជុំជំនួយបច្ចេកទេស (TA) ស្តីពី "ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"

នារសៀលថ្ងៃចន្ទ ១១រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែកក្កដា គ.ស.២០២៥, **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានជួបប្រជុំពិភាក្សា ក្នុងក្របខណ្ឌនៃការអនុវត្តជំនួយបច្ចេកទេស (TA) ស្តីពី "ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ដែលផ្តល់ការគាំទ្រដោយការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



**រូបភាព៖** ពិភាក្សា ក្នុងក្របខណ្ឌនៃការអនុវត្តជំនួយបច្ចេកទេស (TA) ស្តីពី "ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"។

## សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "អនុសាសន៍ទី១៨, ទី១៩, ទី២០, ទី២១ និងទី២៣ និងលទ្ធផលជាក់ស្តែងទី៤"

នាព្រឹកថ្ងៃអង្គារ ១២រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **ឯកឧត្តម ឆេង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** និងក្រុមការងារ បានចូលរួមក្នុងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "អនុសាសន៍ទី១៨, ទី១៩, ទី២០, ទី២១ និងទី២៣ និងលទ្ធផលជាក់ស្តែងទី៤"របស់ក្រុមការងារហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមធ្វើបទបង្ហាញពីគ្រូឧទ្ទេស និងមន្ត្រីជំនាញរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ព្រមទាំងបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ដែលមានសិក្ខាកាមសរុបចំនួន ៣៥ រូប។



**រូបភាព៖** សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ស្តីពី "អនុសាសន៍ទី១៨, ទី១៩, ទី២០,ទី២១ និងទី២៣ និងលទ្ធផលជាក់ស្តែងទី៤"។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៥

នាព្រឹកថ្ងៃពុធ ១៣រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ **ឯកឧត្តម ណឺ សាគល** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាអគ្គលេខាធិការនៃ **អ.គ.ហ.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធ-មុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន តាមប្រព័ន្ធអនឡាញ Zoom.



**រូបភាព៖** កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ-២០២៥។

## កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៧ ឆ្នាំ២០២៥

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៤រោចខែអាសាឍឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម**

**នន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៧ ឆ្នាំ-២០២៥ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។




រូបភាព៖ កម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៧ ឆ្នាំ២០២៥។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នាព្រឹកថ្ងៃសុក្រ ១៥ រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ការបំពេញបន្ថែមលើប្រកាសស្តីពីកម្រៃ-សេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព" របស់និយ័តករបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងសោធនឯកជន" របស់និយ័តករធានារ៉ាប់រងកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំស្តីពី "ប្រតិបត្តិការហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្រោមគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

នៅថ្ងៃពុធ ១៣ រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា គ.ស.២០២៥ (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំស្តីពី "ប្រតិបត្តិការហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្រោមគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, **ឯកឧត្តម ងួន ផារ័ត្ន អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ**, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **Ms. JYOTSANA VARMA** ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំប្រទេសកម្ពុជា នៅសណ្ឋាគារ កំពង់ធំរ៉ូយ៉ាល់ ខេត្ត-កំពង់ធំ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីវឌ្ឍនភាពនៃប្រត្តិបត្តិការហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ដែលកំពុងអនុវត្តដោយអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និងការស្វែងយល់អំពីខ្សែច្រវាក់ផលិតផលសហគមន៍ស្វាយចន្ទី និងសហគមន៍ដំឡូងមីនៅកម្ពុជា។ ជាមួយគ្នានេះ ប្រតិភូក៏បានធ្វើទស្សនកិច្ចចុះត្រួតពិនិត្យអំពីខ្សែច្រវាក់ផលិតកម្មរបស់ក្រុមហ៊ុនសាន់តាណា អាហ្គ្រោ ប្រដាក់ ឯ.ក ដែលជាក្រុមហ៊ុនផលិតនិងកែច្នៃគ្រាប់ស្វាយចន្ទី ស្ថិតក្នុងស្រុករវៀង ខេត្តព្រះវិហារ ផងដែរ។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការជាតិ និងគ្រប់គ្រងបំណុល (GDICDM), អង្គភាពគ្រប់គ្រងគម្រោងមកពី PIU2, ទីប្រឹក្សាគម្រោង (AVCC), តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។




រូបភាព៖ កិច្ចប្រជុំស្តីពី "ប្រតិបត្តិការហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម ក្រោមគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម។

## សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ៣ កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងក្រសួងមហាផ្ទៃ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងឯកឧត្តមឧត្តមសេនីយ៍ **ឯកខិន បាណាល់** អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ នៅសណ្ឋាគារ សុខា ភ្នំពេញ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើង ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់សិក្ខាកាមពីក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ពីដំណើរការបង្កើត ការចុះបញ្ជី និងប្រតិបត្តិការសកម្មភាពក្នុងក្របខណ្ឌបរធនបាលកិច្ចសង្គម។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** តំណាងក្រសួងមហាផ្ទៃ និងតំណាងអង្គការ-សមាគមពាក់ព័ន្ធ។



រូបភាព៖ សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង, ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២៥

នាព្រឹកថ្ងៃអង្គារ ៤កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា គ.ស.២០២៥ **ឯកឧត្តម នេខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋាន, លោកប្រធានស្តីទីនាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០២៥ ព្រម-ទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២៥

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងក្រុមហ៊ុន VTeam Financial Services Group

នាព្រឹកថ្ងៃពុធ ៥ កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រជុំជាមួយ **លោក-**Typhoon Wen ប្រធានក្រុមប្រឹក្សាភិបាលរបស់ VTeam Financial Services Group ដើម្បីពិភាក្សាអំពីកាលានុវត្តភាពវិនិយោគក្នុងទីផ្សារបរធនបាលកិច្ចដែលក្នុងនោះភាគីក្រុមហ៊ុនបានផ្តួចផ្តើមនូវផលិតផលបរធនបាលកិច្ចមួយចំនួនពាក់ព័ន្ធនឹងការជំរុញវិស័យកសិកម្មដូចជាការនាំចេញអង្ករ និងគ្រាប់ស្វាយចន្ទី ទៅកាន់ទីផ្សារអន្តរជាតិ និងវិស័យទេសចរណ៍ ព្រមទាំង ការផ្តល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តាមរយៈយន្តការបរធនបាលកិច្ច។



រូបភាព៖ កិច្ចប្រជុំរវាងថ្នាក់ដឹកនាំនៃ ន.ប.ធ. និងក្រុមហ៊ុន VTeam Financial Services Group។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888